ភ្នំពេញ , ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៣

**សារាចរ លេខ ០៧ សរ**

# សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

**សូមជំរាបមក**

ឯកឧត្តម រដ្ឋមន្ត្រីគ្រប់ក្រសួង

អស់លោក អភិបាលខេត្ត ក្រុង ទូទាំងប្រទេស

**កម្មវត្ថុ :** អំពីការប្រោរព្ធពិធីគោរពទង់ជាតិ ។

**យោង :** សារាចរ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីនាមប្រទេស ទង់ជាតិ ភ្លេងជាតិ និង ព្រះរាជលញ្ឆករ ។

ក្នុងគោលបំណងពង្រឹងពង្រីកខឿនឯករាជជាតិ និង មហាសាមគ្គីជាតិផ្សារភ្ជាប់និង ការពង្រឹងពង្រីក មនសិការស្នេហាជាតិ ស្នេហាមាតុភូមិ ក្រោយព្រះរាជកិច្ចដឹកនាំដ៏ឈ្លាសវៃនៃសម្តេចឪ ជាទីគោរពសក្ការៈដ៏ឧត្តុង្គឧត្តម រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា សូមធ្វើការណែនាំ គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ទូទាំងប្រទេសដូចតទៅ ៖

១- គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង មន្ទីរ អង្គភាពក្រោមឱវាទ មន្ទីរពេទ្យ គ្រឹះស្ថានសិក្សាទូទាំងប្រទេស ត្រូវប្រោរព្ធពិធីគោរពទង់ជាតិ នៅវេលាម៉ោង ៧,០០ ព្រឹក រៀងរាល់ថ្ងៃធ្វើការ ។ ដោយឡែក ចំពោះគ្រឹះស្ថានសិក្សាត្រូវប្រោរព្ធពិធីគោរពទង់ជាតិ ពីរដង ក្នុងមួយថ្ងៃ គឺពេលព្រឹកមុនពេលចូលសិក្សា និង ពេលល្ងាច ក្រោយពេលបញ្ចប់ការសិក្សា ។

២- រោងចក្រហោស្រព រោងភាពយន្ត វីដេអូរដ្ឋ និង ឯកជន នៅទូទាំងប្រទេស ត្រូវធ្វើពិធីគោរពទង់ជាតិ ដោយក្រោកឈរគោរពឆាយាល័ក្ខណ៍សម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ ព្រមទាំងចាក់ភ្លេងជាតិ បទនគររាជ មុននឹងចាប់ផ្តើមដំណើរការសំដែង ឬ បញ្ចាំងសាច់រឿង ។

៣- ក្រសួងឃោសនាការ និង ពត៌មាន ត្រូវចាក់ផ្សាយបន្ត ភ្លេងជាតិបទនគររាជ តាមបណ្តាញវិទ្យុរៀងរាល់ព្រឹកវេលា ម៉ោង ៧,០០ និង ក្រោយពេលបញ្ចប់ការផ្សាយរបស់វិទ្យុ ។ ចំពោះ ទូរទស្សន៍ មុនពេលចាប់ផ្តើម និង ក្រោយពេលបញ្ចប់ នៃ ការផ្សាយ ក៏ត្រូវចាក់ផ្សាយភ្លេងជាតិបទនគររាជ ដែរ ។ ទន្ទឹមនេះ ក្រសួងឃោសនាការ និង ពត៌មានត្រូវបោះពុម្ពខ្លឹមសារបទនគររាជ និង អក្សរភ្លេងជាតិដើម្បីធ្វើការផ្សព្វផ្សាយនៅទូទាំងប្រទេស ។

ក្រោយទទួលបានសារាចរនេះ សូមឯកឧត្តមរដ្ឋមន្ត្រី ប្រធានស្ថាប័ន និង អស់លោកអភិបាល គ្រប់ខេត្ត ក្រុង ទទួលអនុវត្តចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

ព្រះហស្ថលេខា ហត្ថលេខា

ស្ដេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

ភ្នំពេញ , ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣

**សារាចរលេខ ០៨ ស. រ**

**បទបញ្ជា**

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន នៃកម្ពុជា

**សូមទូលថ្វាយ និង ជំរាបជូន**

ព្រះអង្គម្ចាស់ ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ព្រះអង្គម្ចាស់ ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ

**កម្មវត្ថុ :** អំពីករណីជុំវិញការឃោសនា ជ្រើសរើសទ័ព នគរបាល មន្ត្រីរដ្ឋការស៊ីវិល និង ការចាត់តាំងរដ្ឋអំណាចមូលដ្ឋាន ។

**យោងនិងភ្ជាប់ :** សេចក្ដីប្រកាសរបស់រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ។

- សារាចរលេខ ០៥ សរ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងមន្ត្រី និយោជិត សំរាប់ក្រសួង ស្ថាប័ននិមួយៗ ។

សេចក្ដីប្រកាសរបស់រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន នៃ កម្ពុជា ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៣ ។